**ឯកឧត្តម ចម ប្រសិទ្ធ**
**ទទួលជួបលោកជំទាវឯកអគ្គរដ្ឋទូត**
**សាធារណៈរដ្ឋប្រជាមានិតចិន ប្រចាំកម្ពុជា**

នៅរសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានទទួល ជួបលោកជំទាវ **Zhang Jinfeng** ឯកអគ្គរដ្ឋទូតសាធារណៈរដ្ឋប្រជាមានិតចិន ប្រចាំកម្ពុជា ដើម្បីជួប សំដែងការគួរសម និងជំរាបលា ក្នុងឱកាសដែលលោកជំទាវ ត្រូវបានបញ្ចប់អាណត្តិការទូត នៅកម្ពុជា ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានសំដែងការស្វាគមន៍ និងវាយតំលៃខ្ពស់ចំពោះបេសកកម្មការទូត របស់លោកជំទាវ ឯកអគ្គរដ្ឋទូត ដែលបានធ្វើឱ្យ ទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ ត្រូវបានពង្រឹងពង្រីក ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងក្របខ័ណ្ឌអាស៊ីខាងកើត លើកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច-ពាណិជ្ជកម្ម និងការវិនិយោគ ។ ជាពិសេសគឺការជួយទ្រទ្រង់ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា តាមរយៈការផ្តល់ជំនួយជាច្រើនក្នុងការស្តារនិងបង្កើតបន្ថែម នូវហេដ្ឋារចនាសម្ព័ន្ធដើម្បីជាប្រយោជន៍ក្នុងការធ្វើពាណិជ្ជកម្មរវាងប្រជាជន នៃប្រទេសទាំងពីរ ។

លោកជំទាវ **Zhang Jinfeng** ឯកអគ្គរដ្ឋទូត បានសំដែងការរីករាយចំពោះការបំពេញបេសកកម្មការទូត នៅកម្ពុជា ស្ថិតក្នុងលក្ខណៈមិត្តភាព និងកិច្ចសហប្រតិបត្តិការយ៉ាងប្រសើរ រវាងកម្ពុជា-ចិន ដែលជាការកត់សំគាល់ មានចំនួនបីគឺ ៖ ១.ការសំរេចបាន មុនផ្លូវការនៅឆ្នាំ ២០០៨ នូវគោលដៅពង្រីក វិស័យពាណិជ្ជកម្ម រវាងប្រទេសទាំងពីរឱ្យសំរេចបានលើស ១០០០ លានដុល្លារ ដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ប្រមុខរដ្ឋ វិន ចៃ ប៉ាវ **(Wen Jiabao)** បានប្តេជ្ញានៅឆ្នាំ ២០០៦ ដើម្បីសំរេចឱ្យបាននៅឆ្នាំ ២០១០ ២. ទោះបីជាក្នុងកាលៈទេសៈសេដ្ឋកិច្ចពិភពលោក មានការធ្លាក់ចុះ ក៏សន្ទុះពាណិជ្ជកម្ម និងទំនាក់ទំនង រវាងប្រទេសទាំងពីរមានការកើនឡើង ៣. កាលានុវត្តភាពថ្មី ដែលផុសចេញ ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ចិន-អាស៊ាន ដែលបានអនុម័ត្រនៅដើមឆ្នាំនេះ នឹងចូលជាធរមានពេញលិញសំរាប់កម្ពុជា នៅឆ្នាំ២០១៥។ ឆ្លងតាមបទពិសោធន៍ដ៏ល្អនេះ លោកជំទាវ បានសុំអនុសាសន៍ពី ឯកឧត្តមទេសរដ្ឋមន្ត្រី សំរាប់ឯកអគ្គរដ្ឋទូត អាណត្តិក្រោយ ក៏ដូចជារដ្ឋាភិបាល នៃសាធារណៈរដ្ឋប្រជាមានិតចិន ដើម្បីពង្រឹង និងពង្រីកវិស័យពាណិជ្ជកម្មនៃ ប្រទេសទាំងពីរ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអបអរសាទរនូវសមិទ្ធិផលដែលប្រទេសទាំងពីរទទួលបានកន្លងមក និងបន្តពង្រឹង វិស័យពាណិជ្ជកម្មរវាងប្រទេសទាំងពីរបន្ថែមទៀត ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** កម្ពុជាបានសាងមិត្តភាព ដ៏ល្អជាមួយបណ្តាប្រទេសផ្សេងៗ ជាពិសេសប្រទេសចិនដែលតែងតែផ្តល់ជំនួយឥតលក្ខណ្ឌ ដើម្បីឱ្យកម្ពុជាសំរេច ទៅបានការអភិវឌ្ឍន៍ ដ៏ប្រសើរ ។ បន្ថែមលើនេះ រដ្ឋាភិបាលទាំងពីរកំពុងតែដើរផ្លូវត្រូវក្នុងការលើទឹកចិត្តអ្នកវិនិយោគ ហើយបន្ថែម លើនេះទៀតគឺការឈានទៅរកវិធីសាស្រ្តកាត់បន្ថយថ្លៃដើមទំនិញតាមរយៈដឹកជញ្ជូនតាមផ្លូវដែក ដែលជាសក្តានុពលក្នុងការប្រកួតប្រជែង

លើទីផ្សារ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបង្ហាញនូវការមើល ឃើញពីការពន្លឿនផ្នែកវិស័យពាណិជ្ជកម្ម តាមរយៈការ ចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ក្នុងបណ្ដាមុខទំនិញជាពិសេស ដែលនឹងអាចនាំឱ្យ ពាណិជ្ជកម្ម កម្ពុជា-ចិន ឈានទៅដល់ ២០០០លាន ដុល្លា ក្នុងឆ្នាំ ២០១២ ដ៏ខ្លីខាងមុខនេះ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី និងលោកជំទាវឯកអគ្គរដ្ឋទូត ក៏បានប្រៀបធៀបចំណងមិត្តភាពរវាង កម្ពុជា-ចិន ទៅនឹងប្រសាសន៍ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលបានលើកឡើងនៅពិព័ណពាណិជ្ជកម្ម ចិន-អាស៊ាន នៅទីក្រុងណាននីងប្រទេសចិន ថា: “ស្ពានមេត្រីភាពរវាង កម្ពុជា-ចិន ត្រូវបានពង្រឹង និងពង្រីកពីស្ពានឈើទៅស្ពានស៊ីម៉ង់ ដែលមាន ២-៣ Lines សងខាងធ្វើដំណើរទៅមក” ។ នេះជាសច្ចភាពនៃការឈានទៅ មុខដ៏ប្រសើរនៃប្រទេសទាំងពីរ ក្នុងវិស័យពាណិជ្ជកម្ម។ ជាថ្មីម្ដងទៀត ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងអំណរ គុណចំពោះលោកជំទាវឯកអគ្គរដ្ឋទូត និងជូនពរចំពោះលោកជំទាវ ទទួលបានជោគជ័យធំៗថែមទៀតក្នុងការបំពេញភារកិច្ចជូនមាតុភូមិ ។